ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

# បទដ្ឋានអនុវត្តបច្ចេកវិទ្យា

# ការត្រួតពិនិត្យជម្ងឺសាទឹក





រៀបចំដោយ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

សហការជាមួយ នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល

ឧបត្ថម្ភដោយ គំរោងការផ្សព្វផ្សាយកសិកម្មកម្ពុជា-អូស្ត្រាលី

**រៀបរៀងដោយៈ លោក ម៉ារី ម៉ាឃ្លីន (Murray Maclean)**

**កាលបរិច្ឆេទៈ ខែ កក្កដា ឆ្នាំ ២០០៦**

© រក្សាសិទ្ធិគ្រប់យ៉ាងៈ គ្រប់បទដ្ឋានអនុវត្តបច្ចេកវិទ្យា (បអប) ទាំងអស់រួមទាំងឯកសារនេះជាកម្មសិទ្ធិរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយសំរេចផ្តល់អោយនាយកដ្ឋានផ្សព្វផ្សាយកសិកម្មធ្វើជាម្ចាស់កម្មសិទ្ធិ ។ រាល់សំណើសុំផលិតបន្ថែម ត្រូវសុំការអនុញ្ញាតសិទ្ធិជាមុន ពីនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ។

# បុព្វកថា

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្រោមកិច្ចសហការគាំទ្រពីទីភ្នាក់ងារអូស្ត្រាលីសំរាប់ការអភិវឌ្ឍន៍អន្តរជាតិ (AusAID) តាមរយៈគំរោងការផ្សព្វផ្សាយកសិកម្ម កម្ពុជា-អូស្ត្រាលី ជំហានទី២ (២០០១ ២០០៦) ដែលមានគោលដៅពង្រឹងស្ថាប័ននិងប្រព័ន្ធផ្សព្វផ្សាយកសិកម្មនៅកម្ពុជា បានខិតខំយ៉ាងពេញទំហឹងដើម្បីធ្វើការពង្រឹង សមត្ថភាពមន្ត្រីផ្សព្វផ្សាយកសិកម្ម ការរៀបចំកសាងផែនការផ្សព្វផ្សាយកសិកម្មស្របតាមគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល តាមរយៈការវិភាគប្រព័ន្ធកេ្សត្រ-បរិស្ថានថ្នាក់ឃុំ សង្កាត់ និងបានចងក្រងជា បទដ្ឋានអនុវត្តបច្ចេកវិទ្យានេះឡើង។

បទដ្ឋានអនុវត្តបច្ចេកវិទ្យានេះ បានចងក្រងដោយអ្នកជំនាញឯកទេស (Subject Matter Specialist) នឹងត្រូវបានឆ្លងការពិនិត្យ ពិគ្រោះយោបល់ និងឯកភាពយល់ព្រមពីគណៈកម្មការបច្ចេកទេស ដែលមានសមាសភាពមកពីនាយកដ្ឋានជំនាញនានា នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និងអ្នកពាក់ពន្ធ័ផ្សេងៗទៀត។ ឯកសារដ៏មានសារៈសំខាន់នេះ គឺជាឯកសារគោលដែលពិពណ៌នាអំពី ព័ត៌មានបច្ចេកទេសវិធីសាស្ត្រ នីតិវិធី និងផែនការថវិកាចំណាយសម្រាប់ជួយដល់ មន្ត្រីកសិកម្មស្រុក និងភ្នាក់ងារប្រតិបត្តិនៅមូលដ្ឋាន នានាយកទៅប្រើប្រាស់ក្នុងការបណ្តុះ បណ្តាល និងផ្សព្វផ្សាយបច្ចេកទេសថ្មីៗ ក្នុងបំណងផ្ទេរចំណេះដឹង ព័ត៌មាន និងបច្ចេកវិទ្យាកសិកម្ម តាមគ្រប់រូបភាពឱ្យបានជ្រួតជ្រាបដល់ប្រជាកសិករ និង ផលិតករដែលរស់នៅក្នុងតំបន់មានសក្តានុពលភាពស្របតាមលក្ខខ័ណ្ឌភូមិសាស្ត្រ សេដ្ឋកិច្ចសង្គម និងតម្រូវការចាំបាច់ជាក់លាក់នៅមូលដ្ឋាន ។

ដូច្នេះបទដ្ឋានអនុវត្តបច្ចេកវិទ្យានេះ មានសារៈប្រយោជន៍ជារួមសម្រាប់មន្ត្រីកសិកម្មខេត្ត-ក្រុង យកទៅប្រើប្រាស់ក្នុងការចូលរួមដោះស្រាយបញ្ហាចំពោះមុខ ដែលប្រជាកសិករយើងកំពុងប្រឈមមុខនៅក្នុងការធ្វើផលិតកម្មកសិកម្ម ពិពិធកម្មកសិកម្ម ដើម្បីធានាសន្តិសុខស្បៀង និងបង្កើនប្រាក់ចំណូលគ្រួសារ ជាពិសេសរួមចំណែកកាត់បន្ថយភាពក្រីក្រ ស្របតាមយុទ្ធសាស្ត្រ ចតុកោណរបស់រាជរដ្ឋាភិបាល ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គាំទ្រនូវឯកសារបទដ្ឋានអនុវត្តបច្ចេកវិទ្យានេះ ដែលជាឯកសារគោលសម្រាប់មន្ត្រីកសិកម្មស្រុក ខេត្ត-ក្រុង អង្គការក្រៅរដ្ឋាភិបាល ភ្នាក់ងារប្រតិបត្តិនានានៅមូលដ្ឋាន និង អ្នកពាក់ព័ន្ធទាំងអស់យកទៅអនុវត្តក្នុងការផ្ទេរបច្ចេកវិទ្យាដល់ប្រជាកសិករនៅជនបទឱ្យទូលំទូលាយ និងទទួលបានផ្លែផ្កាល្អប្រសើរ ប្រកបដោយក្តីសង្ឃឹម។

**រដ្ឋមន្ត្រី**

## អារម្ភកថា

ពាក្យពេញនៃ **បអប** គឺ “បទដ្ឋានអនុវត្តបច្ចេកវិទ្យា”។ បអប ពន្យល់ពីរបៀបអនុវត្តបច្ចេកវិទ្យា ដើម្បីជួយដោះស្រាយបញ្ហាផ្នែកកសិកម្មរបស់កសិករ។ បអប ផ្ទុកនូវព័ត៌មានបទដ្ឋាន និងសំភារៈសម្រាប់អោយមន្ត្រីផ្សព្វផ្សាយផ្ទេរ បច្ចេកវិទ្យានេះទៅកសិករ។ គោលគំនិតនៃបអប គឺដើម្បីផ្សព្វផ្សាយដល់ឃុំ ស្រុក និងខេត្តនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។ បអប ត្រូវបានគេសរសេរសម្រាប់អោយមន្ត្រីផ្សព្វផ្សាយ អង្គការក្រៅរដ្ឋាភិបាល និងផ្នែកផ្សេងៗទៀត ដែលបំរើការនៅក្នុងវិស័យអភិវឌ្ឍន៍កសិកម្ម នៅតាមមូលដ្ឋានប្រើប្រាស់ ។ បអប មានលក្ខណៈដូចខាងក្រោមនេះ ៖

- អាចបត់បែនបាន-បអប អាចយកទៅអនុវត្តបាននៅគ្រប់ទីកន្លែងក្នុងព្រះរាជាណាចក្រកម្ពុជា
- សាមញ្ញ-បអប អាចប្រើប្រាស់បានដោយគ្រប់ផ្នែកដែលបំរើការនៅតាមមូលដ្ឋាន
- ងាយយល់-ងាយស្រួលក្នុងការផ្តល់នូវព័ត៌មានសំខាន់ៗ

បអប ត្រូវបានកំណត់អាទិភាពដោយផ្អែកទៅតាមបញ្ហាផ្នែកកសិកម្មសំខាន់ៗរបស់កសិករ តាមរយៈប្រភពជាច្រើន ដូចជា ប្រព័ន្ធគ្រប់គ្រងព័ត៌មានរបស់នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម (FSMIS) ដែលផ្ទុកនូវព័ត៌មានសំខាន់ៗរបស់កសិករ។ បញ្ហាផ្នែកកសិកម្មរបស់កសិករ ត្រូវបានគេវិភាគតាមរយៈការវិភាគប្រព័ន្ធកេ្សត្រ-បរិស្ថានថ្នាក់ឃុំ (AEA) នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។ បអប មាននៅតាមស្ថាប័ននានាដូចខាងក្រោមៈ

- វិទ្យាស្ថានស្រាវជ្រាវជាតិ
- ក្រុមកសិករ
- អង្គការក្រៅរដ្ឋាភិបាល
- ទីភ្នាក់ងារស្រាវជ្រាវអន្តរជាតិ
- កម្មវិធីផ្សព្វផ្សាយ
- ម្ចាស់ជំនួយ
- ផ្នែកឯកជន

បអបត្រូវបានគ្រប់គ្រងដោយនាយកដ្ឋានផ្សព្វផ្សាយកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ បអប ត្រូវបានសរសេរដោយអ្នកឯកទេសដែលមានបទពិសោធន៍នៅក្នុងព្រះរាជាណាចក្រ កម្ពុជា ។ ដូច្នេះ បអប ផ្ទុកនូវបទពិសោធន៍ល្អៗសម្រាប់អនុវត្តបច្ចេកវិទ្យា។ បអប ត្រូវបានឆ្លងកាត់ការត្រួតពិនិត្យរបស់ក្រុមការងារ បអប បន្ទាប់មកអនុម័ត និងអនុញ្ញាតដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសម្រាប់ប្រើប្រាស់នៅតាមមូលដ្ឋាន។

## មាតិកា


**១. សេចក្ដីអធិប្បាយ ........................................ ១**

**២. គោលការណ៍ណែនាំបច្ចេកទេស ........................................ ២**

*២.១- សង្ខេបនៃការណែនាំបច្ចេកទេស ........................................ ២*

*២.២- ការកត់សំគាល់លើការណែនាំបច្ចេកទេស ........................................ ២*

២.២.១ ចាក់ថ្នាំការពារជម្ងឺសាទឹកគោ-ក្របីរបស់អ្នកមុនពេលរដូវផ្ទុះជម្ងឺសាទឹកមកដល់ ........................................ ២

*២.២.២. សូមប្រយ័ត្ន កុំដាក់សត្វឈឺឱ្យនៅក្បែរសត្វជា ........................................ ៥*

*២.៣ ផលចំណេញផ្នែកសេដ្ឋកិច្ច ........................................ ៥*

**៣. ការណែនាំលើការខារផ្សព្វផ្សាយ ........................................ ៦**

*៣.១- ការរៀបចំស្ថាប័ន ........................................ ៦*

*៣.២- ផែនការសកម្មភាព ........................................ ៧*

*៣.៣ ឧបករណ៍, សំភារៈ ........................................ ១១*

*៣.៤ ថវិកាសម្រាប់ការធ្វើបង្ហាញ ........................................ ១២*

*៣.៥ កន្លែងអនុវត្តគំរោង ........................................ ១៤*

**៤. ឧបសម្ព័ន្ធ ........................................ ១៥**

៤.១ ឧបសម្ព័ន្ធទី១ : សៀវភៅសម្រាប់អ្នកគ្រប់គ្រងស្រុក ........................................ ១៥

៤.២ ឧបសម្ព័ន្ធទី២ : កំណត់ត្រារបស់ភ្នាក់ងារសុខភាពសត្វភូមិ ........................................ ១៧

៤.៣ ឧបសម្ព័ន្ធទី ៣ : ខិត្តប័ណ្ណព័ត៌មានអំពីជម្ងឺសាទឹក ........................................ ១៨

៤.៤ ឧបសម្ព័ន្ធទី ៤ : ផ្ទាំងរូបភាពសម្រាប់ផ្សព្វផ្សាយអំពីថ្ងៃចាក់វ៉ាក់សាំងជម្ងឺសាទឹក ........................................ ១៩

៤.៥ ឧបសម្ព័ន្ធទី ៥ : ប័ណ្ណតំណាងសាច់ប្រាក់ ចាក់វ៉ាក់សាំងជម្ងឺសាទឹក ........................................ ២០

៤.៦ ឧបសម្ព័ន្ធទី ៦ : ខិត្តប័ណ្ណក្រោយពេលចាក់វ៉ាក់សាំងជម្ងឺសាទឹក ........................................ ២១

៤.៧ ឧបសម្ព័ន្ធទី ៧ : ក្តារខៀន ផ្សព្វផ្សាយពីការចាក់វ៉ាក់សាំងជម្ងឺសាទឹក ........................................ ២២

៤.៨ ឧបសម្ព័ន្ធទី ៨ : ប័ណ្ណព័ត៌មានខ្លីៗសម្រាប់ផ្សព្វផ្សាយជម្ងឺសាទឹក ........................................ ២៣

## ១. សេចក្ដីអធិប្បាយ

**ឈ្មោះអត្ថបទ** ការត្រួតពិនិត្យជម្ងឺសាទឹក

**កាលបរិច្ឆេទ** ខែមករា ឆ្នាំ ២០០៦

**ប្រភពបទដ្ឋានអនុវត្តបច្ចេកវិទ្យា** Murray Maclean

**គោលបំណង និងសារៈប្រយោជន៍**

បង្កើនជីវភាពរស់នៅរបស់កសិករដោយការពារសត្វគោ-ក្របីកុំឱ្យឈឺ និងងាប់ដោយសារជម្ងឺសាទឹក។ ដោយជម្ងឺនេះដំបូងវាយប្រហារលើគោ-ក្របីក្មេង ហើយសត្វអាចងាប់ដែលធ្វើឱ្យកសិករខាតបង់ថវិកា ពី ១-២ លានរៀល ទៅតាមប្រភេទ អាយុ ពូជ និងភេទរបស់សត្វ។

វានឹងធ្វើឱ្យប្រសើរឡើងទំនាក់ទំនងរវាងអ្នកបច្ចេកទេសនិងអ្នកជំនាញខាងផ្សព្វផ្សាយនិងបណ្ដាអ្នកពាក់ព័នដទៃទៀត មានភ្នាក់ងារសុខភាពសត្វភូមិ អ្នកផ្សព្វផ្សាយ និងមន្ត្រីបច្ចេកទេស ។

**លក្ខខ័ណ្ឌសមស្របទៅតាមបច្ចេកទេស**

តំបន់ដែលមានប្រវត្តិផ្ទុះជម្ងឺសាទឹកគោ-ក្របីការចូលទិន្នន័យសំខាន់ៗ

- ការចូលរួមដ៏សកម្មពីភ្នាក់ងារសុខភាពសត្វភូមិ ដើម្បីផ្ដល់សេវាសុខភាពសត្វ។ ភ្នាក់ងារសុខភាពសត្វភូមិគឺមានប្រសិទ្ធភាព ប្រសិនបើកសិករនៅក្នុងភូមិដឹង និងជឿជាក់លើភ្នាក់ងារសុខភាពសត្វភូមិក្នុងការព្យាបាលសត្វឈឺ។ ការិយាល័យផលិតកម្ម និងបសុព្យាបាល និងអង្គការក្រៅរដ្ឋាភិបាល អាចជាប្រភពពត៌ិមានមួយ ថាតើភ្នាក់ងារសុខភាពសត្វភូមិមានប្រសិទ្ធភាព ឬអត់។ ការចុះមើលនៅភូមិ និងជួបជាមួយកសិករ និងភ្នាក់ងារសុខភាពសត្វភូមិ ជាមធ្យោបាយដ៏ល្អបំផុតដើម្បីកំណត់អំពីប្រសិទ្ធភាពរបស់ភ្នាក់ងារសុខភាពសត្វ ភូមិ។
- មន្ត្រីបសុពេទ្យស្រុកដែលមានប្រសិទ្ធភាព
- ថ្នាំការពារជម្ងឺសាទឹក

“ បទដ្ឋានអនុវត្តន៍បច្ចេកវិទ្យា ”នេះ គឺកំណត់គោលដៅលើគ្រប់កសិករដែលចិញ្ចឹមគោ-ក្របី ដូច្នេះលក្ខណៈសេដ្ឋកិច្ចនៃកសិករដែលបានទទួលគឺមានការប្រែប្រួលពីក្រុមកមាន ។

កសិករគ្រាន់តែចំណាយថវិកា ៥០០រៀលក្នុងមួយក្បាល គោ-ក្របី ដើម្បីចាក់ថ្នាំការពារជម្ងឺសាទឹក ។

## ២. គោលការណ៍ណែនាំបច្ចេកទេស

### *២.១- សង្ខេបនៃការណែនាំបច្ចេកទេស*

ក. ចាក់ថ្នាំការពារជម្ងឺសាទឹកគោ-ក្របីរបស់អ្នកមុនពេលរដូវផ្ទុះជម្ងឺសាទឹកមកដល់

ខ. សូមប្រយ័ត្ន កុំឱ្យសត្វឈឺប៉ះពាល់ជាមួយសត្វជា

### *២.២- ការកត់សំគាល់លើការណែនាំបច្ចេកទេស*

#### ២.២.១ ចាក់ថ្នាំការពារជម្ងឺសាទឹកគោ-ក្របីរបស់អ្នកមុនពេលរដូវផ្ទុះជម្ងឺសាទឹកមកដល់

*ជម្ងឺសាទឹកនៅក្នុងប្រព័ន្ធកសិកម្មបុរាណនៅកម្ពុជា*

ក្នុងប្រទេសកម្ពុជាជម្ងឺសាទឹក បង្កឡើងដោយបាក់តេរីដែលរស់នៅក្នុងបំពង់កសត្វដែលផ្ទុកជម្ងឺ ដែលមិនបង្ហាញរោគសញ្ញាហើយរីករាលដាលដល់សត្វដទៃទៀតដែលស្ថិតក្នុងលក្ខខ័ណ្ឌមិនល្អ តួយ៉ាងដូចជា ក្នុងកំឡុងពេលការប្រែប្រួលនៃអាកាសធាតុ ឬពេលសត្វធ្វើការហួសកំលាំង។

នៅក្នុងប្រទេសកម្ពុជា ជម្ងឺសាទឹកជាជម្ងឺឆ្លងពីសត្វទៅសត្វ។ ជាទូទៅវាកើតឡើងក្នុងទំរង់ដូចការផ្ទុះជម្ងឺ។ គោ និងក្របីក្មេង ភាគច្រើនងាយទទួលនូវជម្ងឺនេះណាស់ជាពិសេសក្របី។ ជាធម្មតាជម្ងឺសាទឹកច្រើនកើតនៅរដូវវស្សា។ បាក់តេរីចូលទៅក្នុងឈាមសត្វដែលឈឺ ដោយបង្ហាញនូវរោគសញ្ញាដូចជា:

- សត្វមានសីតុណ្ហភាពខ្ពស់ ហើយបន្ទាប់មកឈឺយ៉ាងស្រួចស្រាវ
- បំពង់ក ក្បាល និងពោះ ឡើងហើមប៉ោង
- សត្វនឹងងាប់ ប្រសិនបើមិនមានការព្យាបាលឱ្យបានទាន់ពេលវេលាទេនោះ

បាក់តេរីរីករាលដាលតាមរយៈការប៉ះពាល់ផ្ទាល់រវាងសត្វដែលផ្ទុកជម្ងឺដែលមិនបញ្ចេញរោគសញ្ញា ឬ សត្វឈឺ និងសត្វជា ឬតាមរយៈសត្វជាប៉ះជាមួយកន្លែងដែលកខ្វក់ ដូចជាប៉ះពាល់ភក់ដែលមានបាក់តេរី។ បាក់តេរីអាចរស់នៅក្នុងបរិយាកាសក្នុងរយៈពេលខ្លី។





**ក្របីងាយទទួលជម្ងឺសាទឹកជាងគោ ហើយសត្វក្មេង ដូចជាគោ ក្របីក្មេង ងាយទទួលជម្ងឺជាងសត្វចាស់**

ការសំងំនៃជម្ងឺគឺ មានរយៈពេល២-៣ថ្ងៃ។ ដូច្នេះ បាក់តេរីអាចរីកសាយភាយពីសត្វឈឺទៅសត្វដទៃទៀតមានរយៈពេល២-៣ថ្ងៃមុនសត្វដែលឆ្លង ហើយឈឺ ។

សត្វដែលឆ្លងជម្ងឺអាចព្យាបាលយ៉ាងមានប្រសិទ្ធិភាព ប្រសិនបើការព្យាបាល អនុវត្តបានទាន់ពេលវេលានិងប្រើប្រាស់ថ្នាំបានត្រឹមត្រូវ។ ប្រសិនបើសត្វហើមក្បាល បំពង់ក និងពោះ រួចហើយ ការព្យាបាលហាក់បីដូចជាមិនបានទទួលជោគជ័យឡើយ ។

ក្នុងករណីខ្លះ រោគសញ្ញានៃជម្ងឺសាទឹកអាចប្រហាក់ប្រហែលនឹងរោគសញ្ញាជម្ងឺដទៃទៀត ដូច្នេះជាទូទៅការធ្វើរោគវិនិច្ឆ័យច្រើនតែភ័ន្តច្រឡំ។ នៅពេលដែលគោ-ក្របី មានសីតុណ្ហភាពខ្ពស់ យើងសង្ស័យវាជាជម្ងឺសាទឹក បើទោះបីវាប្រហែលជាជម្ងឺផ្សេងពីនេះក៏ដោយ ។

មានវ៉ាក់សាំង ២ប្រភេទសំខាន់ៗ សម្រាប់ចាក់ការពារជម្ងឺសាទឹកៈ

- វ៉ាក់សាំងមានជាតិប្រេង (Oil-based vaccines) ដែលការពារសត្វបាននៅក្នុងរយៈពេល ២-៣ អាទិត្យបន្ទាប់ពីពេលចាក់វ៉ាក់សាំង និងបន្តការការពាររហូតដល់ទៅ ៩-១២ ខែ ។
- វ៉ាក់សាំងមានជាតិអាលុយមីញ៉ូម (alum-based vaccines) ដែលការពារសត្វបាននៅក្នុងរយៈពេល ៧-១០ថ្ងៃ បន្ទាប់ពីពេលចាក់វ៉ាក់សាំង និងបន្តការការពាររហូតដល់ទៅ ៦ខែ។ វ៉ាក់សាំងប្រភេទនេះសំខាន់សម្រាប់ប្រើក្នុងពាក់កណ្តាលពេលផ្ទុះជម្ងឺ ពីព្រោះវាប្រតិកម្មលឿន ។

ការណែនាំអំពីការចាក់វ៉ាក់សាំងៈ

- ត្រូវទុកនៅកន្លែងដែលត្រជាក់ដើម្បីថែរក្សាឱ្យមានប្រសិទ្ធភាពនៅពេលទុកប្រើសម្រាប់រយៈពេលវែង
- ត្រូវចាក់ដោយប្រើបច្ចេកទេសលាងសំអាតជាមួយគ្រប់ប្រភេទវ៉ាក់សាំងទាំងអស់

នៅក្នុងប្រទេសកម្ពុជា នាយកដ្ឋានផលិតកម្ម និងបសុព្យាបាលផ្តល់វ៉ាក់សាំងជម្ងឺសត្វដល់ការិយាល័យផលិតកម្ម និងបសុព្យាបាលខេត្ត-ក្រុងទូទាំងប្រទេសក្នុងន័យដើម្បីធ្វើយុទ្ធនាការចាក់ថ្នាំការពារជម្ងឺសត្វជាប្រចាំ។ នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល ចែកចាយថ្នាំការពារជម្ងឺសត្វទាំងពីរប្រភេទ ទាំងថ្នាំការពារជាតិអាលុយមីញ៉ូម (alumbased vaccine) ដែលទិញមកពីប្រទេសវៀតណាម និងជាតិប្រេង (oil-based vaccine) ផលិតនៅក្នុងទីក្រុងភ្នំពេញ ។

នៅពេលជម្ងឺផ្ទុះឡើងកសិករតែងតែៈ

- ជាទូទៅមុនដំបូង ប្រើឱសថបុរាណក្នុងការព្យាបាល ហើយគ្មានប្រសិទ្ធភាព បន្ទាប់មកទើបប្រាប់ភ្នាក់ងារសុខភាពសត្វភូមិ ឬ បសុពេទ្យដើម្បីធ្វើការព្យាបាល ។

- អាចមិនទាក់ទងជាមួយបសុពេទ្យទេ ព្រោះគាត់ខ្លាចនៅពេលដែលសត្វគាត់ងាប់ បសុពេទ្យមិនអនុញ្ញាតឱ្យគាត់លក់សាច់សត្វដែលងាប់នោះទេ។

ជាទូទៅ កសិករៈ

- ដឹងពីរោគសញ្ញានៃជម្ងឺសាទឹក ដែលភាគច្រើនឃើញរោគសញ្ញាជម្ងឺនេះនៅពេលដូចគ្នា ។
- ជាញឹកញាប់ គាត់គិតថានៅពេលសត្វណាមួយឈឺមានលក្ខណៈស្រួចស្រាវ សត្វនោះកើតជម្ងឺសាទឹក
- ដឹងពីការបើកយុទ្ធនាការចាក់ថ្នាំជម្ងឺសត្វរបស់រដ្ឋាភិបាល ។
- មិនយល់ពីកម្មវិធីចាក់វ៉ាក់សាំងជាប្រចាំដែលរៀបចំដោយរដ្ឋាភិបាលប្រឆាំងនឹងជម្ងឺសាទឹក។ ហើយមិនយល់ពីការចាក់វ៉ាក់សាំងគោ-ក្របីប្រឆាំងនឹងជម្ងឺដទៃទៀត ដូចជា ជម្ងឺអុតក្តាមជាដើម ។
- មិនចង់ចំណាយលុយលើការចាក់វ៉ាក់សាំង នៅពេលឃើញសត្វរបស់គាត់នៅមានសុខភាពល្អនៅឡើយ ដែលការចំណាយលើការចាក់វ៉ាក់សាំង មិនអាចឃើញផលប្រយោជន៍មកវិញ។ ជាទូទៅពួកគាត់សង្ឃឹមថារដ្ឋាភិបាល ឬគំរោងអ្វីមួយជាអ្នកចំណាយលើសេវា និងការចាក់វ៉ាក់សាំងសត្វរបស់គាត់។

ដំណើរការល្អៗ បានអនុវត្តអស់រយៈពេលជាច្រើនឆ្នាំមកហើយ ដើម្បីបង្កើនសមត្ថភាពកសិករឱ្យមានការយល់ដឹងពីជម្ងឺសត្វ និងមានឆន្ទៈហ៊ានចំណាយទៅលើការផ្តល់សេវាចាក់ថ្នាំការពារជម្ងឺសត្វ ។

### *សេចក្តីណែនាំអំពីការចាក់វ៉ាក់សាំងជម្ងឺសាទឹក*

គោ-ក្របីដែលមានអាយុលើសពី៣ខែ ត្រូវចាក់វ៉ាក់សាំងប្រឆាំងនឹងជម្ងឺសាទឹក ដើម្បីការពារពួកវាក្នុងរយៈពេលដែលឆាប់ទទួលជម្ងឺ។ ពេលវេលាដែលចាក់វ៉ាក់សាំងជម្ងឺសាទឹកល្អបំផុតគឺមុនពេលរដូវវស្សា និងម្តងទៀតរយៈពេល៦ខែ ក្រោយមក។ រយៈពេលនេះនឹងធានាថា សត្វអាចទប់ទល់នឹងជម្ងឺពេញមួយឆ្នាំ។ លើសពីនេះទៀត សត្វដែលចាក់វ៉ាក់សាំងលើកទី១ ត្រូវចាក់លើកទី២ នៅរយៈពេល១-៣ខែក្រោយមកទៀត។

ពេលដ៏ល្អបំផុតសម្រាប់បង្កើតឱ្យមាននូវយុទ្ធនាការចាក់វ៉ាក់សាំងជម្ងឺសត្វ ជាធម្មតាកំណត់ឡើងដោយការអនុវត្តន៍ នៅក្នុងកសិដ្ឋានតែប៉ុណ្ណោះ។ ហេតុដូច្នេះហើយ ពេលវេលាល្អសម្រាប់ចាក់វ៉ាក់សាំងជម្ងឺសត្វ ជាញឹកញាប់ត្រូវកំណត់ដោយ ពេលណាដែលមានវត្តមានគោ-ក្របីនៅក្នុងភូមិ ហើយកសិករមានពេលនាំគោ-ក្របីពួកគាត់មកដើម្បីចាក់វ៉ាក់សាំង ។

### *ទីផ្សារសម្រាប់ថ្នាំការពារជម្ងឺសត្វ*

ចំនួននៃតំរូវការសម្រាប់វ៉ាក់សាំងជម្ងឺសាទឹក ក្នុងតម្លៃ៥០០រៀលក្នុងមួយក្បាល មានការកើនឡើង។ វាមិនប្រាកដដែរថា ចំនួនតំរូវការនៃវ៉ាក់សាំងនឹងមានប្រសិនបើតម្លៃខ្ពស់ជាងនេះទៀត។ ប៉ុន្តែវាអាចធ្វើទៅបានដែលតម្លៃខ្ពស់ជាងនេះអាចរាប់បញ្ចូលនៅពេលដែលចំនួននៃតំរូវការមានតិចតួច។ ម្យ៉ាងវិញទៀត វាមានសក្តានុពលភាពក្នុងការបង្កើនតម្លៃទៀតផង ។

### ២.២.២. សូមប្រយ័ត្ន កុំដាក់សត្វឈឺឱ្យនៅក្បែរសត្វជា

ប្រសិនបើមានគោ-ក្របីឈឺនៅក្នុងភូមិ អ្នកត្រូវតែប្រាកដថាគោ-ក្របីរបស់អ្នកបានប៉ះពាល់ឬមិនបានប៉ះពាល់ជាមួយនឹងគោ-ក្របីដែលឈឺទាំងនោះ ដែរឬទេ ។

ប្រសិនបើសត្វងាប់ គួរតែកប់វាចោលតាមលក្ខណៈបច្ចេកទេស ហើយមិនត្រូវយកសាច់របស់វាមកធ្វើជាម្ហូបអាហារទេ កសិករគួរតែដឹងពីបញ្ហាជម្ងឺសាទឹកដែលកើតមាននៅក្នុងភូមិ ម្យ៉ាងវិញទៀតកសិករទាំងអស់នៅក្នុងភូមិត្រូវតែចូលរួមក្នុងកម្មវិធីប្រយុទ្ធប្រឆាំងនឹងជម្ងឺសាទឹក។ ប្រសិនបើកសិករមួយចំនួនមិនបានចូលរួម ហើយមិនបានដឹងពីជម្ងឺនេះ នៅពេលដែលមានជម្ងឺសាទឹកផ្ទុះឡើងនៅក្នុងភូមិ ជម្ងឺនេះនឹងបន្តរីករាលដាលទៅសត្វផ្សេងទៀតនៅក្នុងភូមិ ហើយក៏អាចរីករាលដាលដល់សត្វដែលបានចាក់វ៉ាក់សាំងរួចហើយផងដែរ ។

### *២.៣ ផលចំណេញផ្នែកសេដ្ឋកិច្ច*

វាមានគំលាតនៃលទ្ធផលដែលអាចកើតមាន ដែលបណ្តាលមកពីការសំរេចចិត្តរបស់កសិករ ក្នុងការចាក់វ៉ាក់សាំង ឬមិនចាក់វ៉ាក់សាំងជម្ងឺសត្វ រួមមានៈ

- សត្វអាចមាន ឬក៏គ្មានជម្ងឺ
- ប្រសិនបើសត្វមានជម្ងឺ វាប្រហែលជាអាចព្យាបាល ឬមិនអាចព្យាបាលបាន
- ប្រសិនបើព្យាបាល តើការព្យាបាលអាចទទួលជោគជ័យ ឬមិនអាចជោគជ័យ

ការវិភាគសេដ្ឋកិច្ច បានប្រៀបធៀបលទ្ធផលមួយក្នុងចំណោមលទ្ធផលទាំងអស់នេះ ជាមួយនឹងទស្សនៈដែលចាក់វ៉ាក់សាំងជម្ងឺសត្វបានបង្ហាញថា ការអនុវត្តចំពោះផ្ទះកសិករមួយដែលមានគោពូជមួយក្បាល និងគោក្មេងពីរក្បាល។ ក្នុងការវិភាគនេះ ការប្រៀបធៀបមានដូចខាងក្រោមនេះ ៖

- គោទាំងបី បានចាក់ថ្នាំការពារ ជាលទ្ធផលគ្មានគោណាមួយមានជម្ងឺ និងគ្មានការចំណាយទៅលើការព្យាបាលទេ
- គោមិនបានចាក់ថ្នាំការពារ ជាលទ្ធផលគោក្មេងទទួលរងនូវជម្ងឺ ហើយការព្យាបាលមិនទទួលជោគជ័យ រួចហើយសត្វងាប់ ។

**តារាងទី១ ការប្រៀបធៀបសេដ្ឋកិច្ច រវាងការអនុវត្តន៍ និង ការមិនមានការអនុវត្តន៍ការត្រួតពិនិត្យជម្ងឺសាទឹក ចំពោះគ្រួសារដែលមានគោពូជមួយក្បាល និង គោក្មេងពីរក្បាល**

| ការប្រៀបធៀបសេដ្ឋកិច្ចរវាងការដែលអនុវត្ត និងការដែលមិនអនុវត្តការត្រួតពិនិត្យជម្ងឺសាទឹក ចំពោះគ្រួសារដែលមានគោពូជ១ក្បាល និងគោក្មេង២ក្បាល | | | | | | | | |
|---|---|---|---|---|---|---|---|---|
| **បរិយាយ** | **មិនមានអនុវត្តការត្រួតពនិត្យជម្ងឺសាទឹក** | | | | **អនុវត្តការត្រួតពនិត្យជម្ងឺសាទឹក** | | | |
| | **ឯកតា** | **តម្លៃឯកតា** | **ចំនួនឯកតា** | **តម្លៃ(រៀល)** | **ឯកតា** | **តម្លៃឯកតា** | **ចំនួនឯកតា** | **តម្លៃ(រៀល)** |
| **តម្លៃប្រែប្រួល** | | | | | | | | |
| គោងាប់ | ក្បាល | ១ 000 000 | ១ | ១ 000 000 | ក្បាល | ១ 000 000 | 0 | 0 |
| ការព្យាបាល | | ២0 000 | ១ | ២0 000 | | ២0 000 | 0 | 0 |
| វ៉ាក់សាំង | | ៥00 | 0 | 0 | | ៥00 | ៣ | ១ ៥00 |
| **តម្លៃសរុប** | | | | **១ 0២0 000** | | | | **១ ៥00** |

**ចំណាំ**

ប្រសិនបើគ្រួសារនេះមិនបានចាក់ថ្នាំការពារឱ្យគោ៣ក្បាលរបស់គាត់ទេ គោរបស់គាត់នឹងងាយទទួលជម្ងឺសាទឹក ជាពិសេសគោដែលក្មេងជាងគេ ហើយប្រសិនបើការព្យាបាលមិនទាន់ពេលវេលា សត្វរបស់គាត់នឹងងាប់ ។

## ៣. ការណែនាំលើការខារផ្សព្វផ្សាយ

ការណែនាំក្នុងការផ្សព្វផ្សាយ រៀបរាប់អំពីកម្មវិធីផ្សព្វផ្សាយកំរិតឃុំ ។ សេចក្តីណែនាំទាំងនេះ អាចត្រូវបាន អនុម័តឱ្យធ្វើការផ្សព្វផ្សាយទូលំទូលាយគ្រប់តំបន់ ទាំងថ្នាក់ស្រុក និង ខេត្ត ។

### *៣.១- ការរៀបចំស្ថាប័ន*

អ្នកដែលចូលរួមក្នុងកម្មវិធីផ្សព្វផ្សាយ ត្រូវតែជា:

ក- មន្ត្រីនៃការិយាល័យផលិតកម្ម និងបសុព្យាបាល និងមន្ត្រីផ្សព្វផ្សាយកសិកម្មខេត្ត-ក្រុង ។ មន្ត្រីដែល ជាសមាជិកនេះ ត្រូវទទួលខុសត្រូវចំពោះភាពទូទៅនៃកម្មវិធីផ្សព្វផ្សាយ។ ការិយាល័យ ផលិតកម្ម និងបសុព្យាបាល ខេត្ត-ក្រុង ជាអ្នកផ្តល់វ៉ាក់សាំង។

ខ- មន្ត្រីបសុពេទ្យនៃការិយាល័យកសិកម្មស្រុក ក្រោមកិច្ចសន្យាដើម្បី រៀបចំសកម្មភាពការងារនៅ ក្នុងស្រុក។ ប្រធានការិយាល័យកសិកម្មស្រុកនឹងមានតួនាទីជាអ្នកគាំទ្រកម្មវិធីផងដែរ។

គ- ចំពោះភ្នាក់ងារសុខភាពសត្វភូមិ ប្រសិនបើត្រូវបានបញ្ចូលទៅក្នុងសមាគមភ្នាក់ងារសុខភាពសត្វភូមិ នោះការរៀបចំផ្ទៃក្នុងរបស់សមាគមនេះ ត្រូវបានពិចារណា និងយកចិត្តទុកដាក់។ ឧទាហរណ៍ ៖ ប្រធាននៃសមាគម នេះមានតួនាទីសំខាន់ណាស់ក្នុងការដឹកនាំសមាគម។

ឃ- អាជ្ញាធរភូមិ-ឃុំ ជាជំនួយក្នុងការអនុវត្តសកម្មភាពការងារនេះ ។

ង- កសិករចូលរួមផ្តល់ព័ត៌មាន ចំណាយលើការទិញវ៉ាក់សាំង និងផ្តល់ចំលើយតបស្តីពីប្រសិទ្ធភាពនៃកម្មវិធីនេះ ។

## ៣.២- ផែនការសកម្មភាព

ផែនការសកម្មភាពនេះមានរយៈពេលជាង៥ខែ រួមមាន ការបង្ហាញពីផែនការ ការអនុវត្តន៍ និងដំណាក់កាលពិនិត្យឡើងវិញ និងការវាយតម្លៃ។ កាលបរិច្ឆេទដើម្បីអនុវត្តន៍កម្មវិធីនេះ នឹងប្រព្រឹត្តិផ្សេងៗគ្នាទៅតាមឃុំនីមួយៗយោលទៅ តាមចលនាសត្វគោ-ក្របី រដូវកាលធ្វើការងារកសិកម្ម និងទីកន្លែងដែលគិតថានឹងអាចមានជម្ងឺផ្ទុះឡើងទោះបីជាយ៉ាងណាក៏ដោយនៅក្រោយពេលចូលឆ្នាំខ្មែរ មុនពេលរដូវភ្លៀងចាប់ផ្តើម គឺជាពេលដ៏ល្អបំផុតក្នុងការរៀបចំកម្មវិធីចាក់វ៉ាក់សាំងសត្វគោ-ក្របី។ កម្មវិធីចាក់វ៉ាក់សាំងការពារ ត្រូវការចាក់រំលឹកឡើងវិញចំនួន២ដងក្នុងមួយឆ្នាំយោលទៅលើប្រភេទវ៉ាក់សាំង និងចលនាសត្វ។ ប្រសិនបើនេះជាតំរូវការ បន្ទាប់មកជាធម្មតានៅខែតុលា គឺជាខែដ៏ល្អបំផុតសម្រាប់ការចាក់រំលឹកឡើងវិញ។ តារាងទី ១ បង្ហាញពីផែនការសកម្មភាពដែលនឹងគ្រោងចាក់នៅខែឧសភា។

**ក្រាហ្វិកទី១ ផែនការសកម្មភាពសម្រាប់កម្មវិធីការត្រួតពិនិត្យជម្ងឺសាទឹក**

| | ផែនការសកម្មភាពសំរាប់កម្មវិធីត្រួតពិនិត្យជំងឺសាទឹក | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| **សកម្មភាព** | ខែ | | | | | | | | | | | |
| | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| ការជ្រើសរើសទីកន្លែងអនុវត្ត | | | | | | | | | | | | |
| ការប្រជុំនៅក្នុងឃុំលើកទី១,២ និង ៣ | | | | | | | | | | | | |
| ដំណាក់កាលផ្សព្វផ្សាយ | | | | | | | | | | | | |
| ដំណាក់កាលចាក់វ៉ាក់សាំង | | | | | | | | | | | | |
| ការតាមដាន | | | | | | | | | | | | |
| ការត្រួតពិនិត្យអ្នកគ្រប់គ្រងស្រុក | | | | | | | | | | | | |
| ការត្រួតពិនិត្យអ្នកគ្រប់គ្រងខេត្ត | | | | | | | | | | | | |

## ការជ្រើសរើសកន្លែងអនុវត្ត

គ្រប់ភូមិទាំងអស់នៅក្នុងឃុំ ត្រូវបានកំនត់ជាតំបន់គោលដៅចាប់តាំងពីជម្ងឺសាទឹកឆ្លងពីភូមិមួយទៅភូមិមួយ មក ប្រធានការិយាល័យផលិតកម្ម និងបសុព្យាបាលខេត្ត-ក្រុង ត្រូវតែដឹងតំបន់សត្វស៊ីស្មៅ ដូចជាកន្លែងស៊ីស្មៅ និងទឹក។ និងរៀបចំកម្មវិធីត្រួតពិនិត្យជុំវិញតំបន់ទាំងនេះ ដែលមិនត្រួតស៊ីគ្នាជាមួយព្រំដែនឃុំដទៃទៀត។

## ការប្រជុំនៅឃុំលើកទី១

ការប្រជុំ ត្រូវរៀបចំដោយអ្នកចាត់ចែងក្នុងស្រុក និង ចូលរួមដោយអាជ្ញាធរឃុំ និងភ្នាក់ងារសុខភាពសត្វ ភូមិ។ ការប្រជុំមាន:

- ផ្នែកបច្ចេកទេសដែលចូលរួម ត្រូវលើកពីបញ្ហាបច្ចេកទេស និងហិរញ្ញវត្ថុ សម្រាប់កម្មវិធីប្រយុទ្ធ ប្រឆាំងនឹងជម្ងឺសាទឹក និងស្ថានភាពជម្ងឺសាទឹកក្នុងខេត្ត-ក្រុង ស្រុក និងឃុំនាពេលបច្ចុប្បន្ន។ ចំពោះចំនួនគ្រួសារ និងចំនួនសត្វចិញ្ចឹមនៅក្នុងភូមិនីមួយៗនៃឃុំ គួរពិនិត្យឡើងវិញ ។
- ការរំពឹងទុកថវិកាចំពោះកម្មវិធីចាក់ថ្នាំការពារជម្ងឺសាទឹក ។ ថវិកានេះរួមបញ្ចូលការប៉ាន់ប្រមាណនៃតំរូវការចំនួនថ្នាំការពារ និងការចែករំលែកប្រាក់ចំណូល។ ប្រសិនបើប្រព័ន្ធនឹងត្រូវបានគេប្រើ នោះគួរត្រូវមានការពិភាក្សា និងឯកភាព ដោយយោងទៅលើបរិមាណ និងប្រព័ន្ធចែកចាយ។ បរិមាណ និងផែនការចែកចាយ ផ្ទាំងរូបភាព លិខិតណែនាំ គួរត្រូវមានការពិភាក្សា និងឯកភាពជា មុនសិន ។
- ផ្នែករចនាសម្ព័ន្ធដែលត្រូវរៀបរាប់អំពីផែនការសកម្មភាព រួមមាន ការផ្សព្វផ្សាយ ការចាក់វ៉ាក់សាំង ការត្រួតពិនិត្យ និងការវាយតម្លៃ។ ភ្នាក់ងារសុខភាពសត្វភូមិត្រូវបានរៀបចំពី ៣-៤ ក្រុម ដែលចាប់ផ្ដើមពីភូមិនីមួយៗនៅក្នុងឃុំ ឬក៏អាចត្រូវរៀបចំជា១-២ក្រុមអាស្រ័យលើចំនួន និងទំហំរបស់ភូមិ ហើយនិងចំនួនភ្នាក់ងារសុខភាពសត្វភូមិ ។

## ការផ្សព្វផ្សាយ

ភ្នាក់ងារសុខភាពសត្វភូមិ និង អាជ្ញាធរភូមិត្រូវសហការគ្នាជូនដំណឹងដល់កសិករអំពី:

- ពេលវេលា ទីកន្លែង និងតម្លៃថ្នាំការពារជម្ងឺសាទឹក តាមរយៈការបិទផ្ទាំងរូបភាពនៅពាសពេញភូមិ និង តាមរយៈការប្រកាសតាមមីក្រូ ។
- បច្ចេកទេស និងថវិកាសម្រាប់ត្រួតពិនិត្យជម្ងឺសាទឹក តាមរយៈការផ្ដល់ (ខិតប័ណ្ណព័ត៌មានស្ដីពីជម្ងឺសាទឹក)។ នេះរួមបញ្ចូលទាំងព័ត៌មានស្ដីពីការពិតដែលថា ថ្នាំការពារជម្ងឺសាទឹកមិនអាចការពារជម្ងឺដទៃទៀតបានឡើយ ដូចជាជម្ងឺអុតក្ដាម ។
- បច្ចេកទេស និងថវិកាសម្រាប់ត្រួតពិនិត្យជម្ងឺសាទឹក តាមរយៈការប្រជុំកសិករ នៅពេលដែលប្រើប្រាស់ផ្ទាំងបដារូបភាពអំពីជម្ងឺសាទឹក ។

➢ សារៈសំខាន់នៃការចាក់វ៉ាក់សាំងការពារជម្ងឺសាទឹកដោយបិទបដារូបភាពនៅក្នុងឃុំ ។

ភ្នាក់ងារសុខភាពសត្វភូមិរៀបចំចាក់វ៉ាក់សាំងលើគោ-ក្របីពី ៣-៤ក្បាល ជាលក្ខណៈបង្ហាញនៅក្នុងមូលដ្ឋាន សាលារៀន និងចែកខិត្តប័ណ្ណ និងផ្ទាំងរូបភាពជូនដល់សិស្សានុសិស្ស ។

ផ្នែកមួយដែលសំខាន់ក្នុងចំណោមសកម្មភាពផ្សព្វផ្សាយទាំងអស់ គឺកសិករដែលបានទទួលព័ត៌មានស្តីពីជម្ងឺសាទឹករួចហើយ ប្រសិនបើពួកគាត់ចង់ចាក់វ៉ាក់សាំងឱ្យសត្វរបស់គាត់ ពួកគាត់ត្រូវចំណាយលើថ្លៃវ៉ាក់សាំង ដែលជាទូទៅមានតម្លៃ ៥០០រៀល។

សកម្មភាពទាំងនេះ ត្រូវចាត់ចែងដោយភ្នាក់ងារសុខភាពសត្វភូមិនៅក្នុងភូមិរបស់ពួកគេ រយៈពេល១-២ថ្ងៃមុនពេលថ្ងៃចាក់វ៉ាក់សាំងសត្វមកដល់ ។ ភ្នាក់ងារសុខភាពសត្វភូមិត្រូវរៀបចំធ្វើកន្លែងចាក់វ៉ាក់សាំង ដោយយោលទៅលើទំហំរបស់ភូមិ អាចធ្វើលើសពីមួយថ្ងៃក្នុងមួយកន្លែង ។




ក្តារខៀនផ្សព្វផ្សាយ ដើម្បីបង្កើនការយល់ដឹង អំពីសារៈសំខាន់នៃការចាក់ថ្នាំបង្ការជំងឺសាទឹក ។ ក្តារខៀនបិទនៅតាមផ្លូវ និងក្បែរទីផ្សារ

**ដំណាក់កាលចាក់វ៉ាក់សាំង**

**ភ្នាក់ងារសុខភាពសត្វភូមិ ធ្វើដំណើរជាក្រុមត្រួតពិនិត្យតាមភូមិនីមួយៗ ដើម្បី**

➢ ចាក់វ៉ាក់សាំងដល់សត្វ

➢ ប្រមូលថ្លៃសេវាចាក់ថ្នាំ

➢ កត់ត្រាកាលបរិច្ឆេទនៃការចាក់វ៉ាក់សាំង

➢ ផ្តល់ **"ខិត្តប័ណ្ណក្រោយចាក់វ៉ាក់សាំងជម្ងឺសាទឹក"** ដល់កសិករ ក្រោយពេលសត្វរបស់ពួកគេបានចាក់វ៉ាក់សាំងរួចហើយ ។

ក្នុងករណីខ្លះ វាអាចជាគំនិតល្អមួយសម្រាប់ក្រុមភ្នាក់ងារសុខភាពសត្វភូមិ ដើម្បីចាក់ថ្នាំការពារដល់ គោ-ក្របី នៅក្នុងភូមិរបស់គាត់ និងភូមិដទៃទៀត។ និន្នាការនេះ គឺដើម្បីបង្កើនប្រាក់ចំណូល។

ប្រសិនបើការចាក់វ៉ាក់សាំងកំពុងត្រូវបានគេអនុវត្តនៅក្នុងឃុំជាច្រើន ភ្នាក់ងារសុខភាពសត្វភូមិ អាចចាក់វ៉ាក់សាំងសត្វដល់ឃុំដទៃទៀតក្រៅពីឃុំរបស់ខ្លួន។

**ការប្រជុំនៅក្នុងឃុំលើកទី ២**

បន្ទាប់ពីដំណាក់កាលចាក់វ៉ាក់សាំងបានបញ្ចប់ ភ្នាក់ងារសុខភាពសត្វភូមិទាំងអស់ត្រូវជួបជុំទាំងអស់គ្នាជាមួយនឹងមេស្រុកម្តងទៀតដើម្បីវាយតម្លៃបច្ចេកទេស និងលទ្ធផលហិរញ្ញវត្ថុនៃកម្មវិធីចាក់ថ្នាំការពារជម្ងឺសត្វ។ ទាំងនេះរួមបញ្ចូល ការប្រៀបធៀបរវាងក្រុមនិងក្រុម ការពិភាក្សាពីភាពខ្លាំង និងភាពខ្សោយ និងសំណូមពរសម្រាប់កែលំអទៅថ្ងៃអនាគត។




. ការប្រជុំរៀបចំឡើងនៅក្នុងឃុំរវាងអ្នកបច្ចេកទេសស្រុក ភ្នាក់ងារសុខភាពសត្វភូមិ និងអាជ្ញាធរមូលដ្ឋាន សំរាប់ធ្វើផែនការ ត្រួតពិនិត្យ និង វាយតំលៃ

**ការតាមដាន**

ភ្នាក់ងារសុខភាពសត្វភូមិ បន្តការត្រួតពិនិត្យស្ថានភាពសុខភាពសត្វនៅក្នុងភូមិ និងធ្វើការតាមដានការចាក់វ៉ាក់សាំងដល់សត្វក្មេងដែលបានចាក់ថ្នាំការពាររហើយលើកទី១។ ភ្នាក់ងារសុខភាពសត្វភូមិ ត្រូវតែរាយការណ៍អំពីការផ្ទុះជម្ងឺណាមួយលើគោ-ក្របី ក្នុងកំឡុងពេលដែលចាក់វ៉ាក់សាំងលើកដំបូងរួចដល់មេស្រុក។ ភ្នាក់ងារសុខភាពសត្វភូមិ ត្រូវតែត្រួតពិនិត្យគ្រប់សត្វទាំងអស់ដែលអាចកើតមានអាប់សែ ដែលបណ្តាលមកពីការចាក់ថ្នាំការពារ ។

**ការត្រួតពិនិត្យអ្នកសំរបសំរួលថ្នាក់ស្រុក**

មេស្រុកគួរតែទៅទស្សនៈកិច្ចជាប្រចាំ និងដោយចៃដន្យក្នុងកំឡុងពេលដំណាក់កាលផ្សព្វផ្សាយ និងការអនុវត្តការងារដើម្បីត្រួតពិនិត្យរាល់សកម្មភាពរបស់ភ្នាក់ងារសុខភាពសត្វភូមិ ។ អ្នកសំរបសំរួលថ្នាក់ខេត្តត្រូវតែចុះទៅទស្សនៈកិច្ចនៅឃុំ យ៉ាងហោចណាស់មួយដងក្នុងកំឡុងពេលការងារចាប់ផ្តើមអនុវត្ត ។

**ការប្រជុំថ្នាក់ឃុំលើកទី ៣**

ក្រោយពេលដំណាក់កាលចាក់ថ្នាំការពារបានបញ្ចប់ ភ្នាក់ងារសុខភាពសត្វភូមិទាំងអស់ ត្រូវប្រជុំជាមួយនឹងអ្នកគ្រប់គ្រងថ្នាក់ស្រុក និងអ្នកសំរបសំរួលថ្នាក់ខេត្តម្តងទៀត ដើម្បីវាយតម្លៃលើបច្ចេកទេស និងថវិកា ដែលបានមកពីកម្មវិធីចាក់វ៉ាក់សាំង និងក្នុងកំឡុងពេលតាមដាន ។

## *៣.៣ ឧបករណ៍, សំភារៈ*

ឧបករណ៍ និងសំភារៈខាងក្រោម គឺត្រូវការចាំបាច់ដើម្បីអនុវត្តគំរោងផ្សព្វផ្សាយ ។

**តារាងទី២ បញ្ជីឈ្មោះឧបករណ៍ និងសំភារៈ**

| |
|---|
| សៀវភៅសម្រាប់អ្នកគ្រប់គ្រងក្នុងភូមិ |
| សៀវភៅកត់ត្រាសម្រាប់អ្នកគ្រប់គ្រងក្នុងភូមិ |
| ក្តារខៀនផ្សព្វផ្សាយពីជម្ងឺសាទឹក |
| ខិត្តប័ណ្ណព័ត៌មានជម្ងឺសាទឹក |
| ផ្ទាំងរូបភាពថ្ងៃចាក់វ៉ាក់សាំងជម្ងឺសាទឹក |
| ខិត្តប័ណ្ណក្រោយពេលចាក់វ៉ាក់សាំងជម្ងឺសាទឹក |
| ប័ណ្ណតំណាងសាច់ប្រាក់ |
| ឯកសារបច្ចេកទេសជម្ងឺសាទឹកសម្រាប់ភ្នាក់ងារសុខភាពសត្វភូមិ |

សៀវភៅបណ្តុះបណ្តាលភ្នាក់ងារសុខភាពសត្វភូមិ អាចរកបាននៅការិយាល័យផលិតកម្ម និងបសុព្យាបាលខេត្ត ដែលជាប្រភពព័ត៌មានស្តីពីបញ្ហាសុខភាព និងការគ្រប់គ្រងសត្វ ដូចជា ខិត្តប័ណ្ណ ផ្ទាំងរូបភាព ក្តារខៀនរូបភាព និងសៀវភៅកត់ត្រា ដែលមាននៅក្នុងឧបសម្ព័ន្ធ។

ប្រព័ន្ធប័ណ្ណតំណាងសាច់ប្រាក់ គឺជាជម្រើសដ៏ល្អមួយ ហើយប្រព័ន្ធប័ណ្ណតំណាងសាច់ប្រាក់ គឺធ្វើការងារដូចខាងក្រោម

- ប័ណ្ណតំណាងសាច់ប្រាក់នៃចំនួនដែលបានកំណត់ក្នុងមួយភូមិ ត្រូវបានចែកជូនកសិករដែលសមស្របតាម លក្ខខ័ណ្ឌជ្រើសរើស (តួយ៉ាងដូចជា កសិករដែលក្រីក្រមានគោតែមួយក្បាល) ដោយប្រធាន

ភូមិក្នុងកំឡុងពេលផ្សព្វផ្សាយ។ ប័ណ្ណតំណាងសាច់ប្រាក់ទាំងនេះ មានតម្លៃ ៥០០រៀល (តម្លៃថ្នាំការពារមួយដូស) ហើយតម្លៃ និងគោលបំណងនៃប័ណ្ណតំណាងសាច់ប្រាក់នេះ មានបង្ហាញជូននៅលើប័ណ្ណតំណាងសាច់ប្រាក់។ មេភូមិ ធ្វើការកត់ត្រាចំនួនប័ណ្ណតំណាងសាច់ប្រាក់ដែលបានចែកចាយ និងការផ្តល់ដល់ភ្នាក់ងារសុខភាពសត្វភូមិ។

- កសិករ ត្រូវរក្សាទុកប័ណ្ណតំណាងសាច់ប្រាក់នេះរហូតដល់ថ្ងៃចាក់វ៉ាក់សាំងមកដល់
- កសិករ ត្រូវអោយប័ណ្ណតំណាងសាច់ប្រាក់នេះដល់ភ្នាក់ងារសុខភាពសត្វភូមិ ជំនួសថវិកាចំណាយលើការចាក់វ៉ាក់សាំង។
- ភ្នាក់ងារសុខភាពសត្វភូមិ បង្ហាញប័ណ្ណតំណាងសាច់ប្រាក់នេះនៅពេលប្រជុំថ្នាក់ឃុំបញ្ចប់ និងទូទាត់យោលទៅលើចំនួននៃប័ណ្ណតំណាងសាច់ប្រាក់។

គោលបំណងនៃការរៀបចំប្រព័ន្ធប័ណ្ណតំណាងសាច់ប្រាក់នេះ គឺដើម្បីពង្រីកទស្សនៈនៃកម្មវិធីការផ្សព្វផ្សាយ និងទុកសម្រាប់ការប្រើប្រាស់មូលនិធិឱ្យចំក្រុមគោលដៅនៅក្នុងភូមិ។ វាតំរូវឱ្យមានបែបបទរដ្ឋបាលខ្លះ។ ទាំងនេះប្រហែល ជាសមស្របទៅនឹងស្ថានភាពខ្លះ និងមិនសមស្របខ្លះ ។ ដូច្នេះ វាជាសកម្មភាពមួយដែលមានប្រយោជន៍។

## ៣.៤ ថវិកាសម្រាប់ការធ្វើបង្ហាញ

ថវិកាសម្រាប់កម្មវិធីផ្សព្វផ្សាយ នឹងប្រែប្រួលអាស្រ័យលើតំរូវការជាក់ស្តែងនៃសាមីអង្គភាព ។ តារាងថវិកាខាងក្រោមបាន បង្កើតឡើងក្នុងឆ្នាំ២០០៦ ដោយយោងទៅលើការប៉ាន់ស្មានលើបទដ្ឋានអនុវត្តបច្ចេកវិទ្យារបស់នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម:

**តារាងទី ៣ ថវិកាសម្រាប់អនុវត្តន៍គម្រោង**

| **ថវិកា និង ការសន្មត់** | ចំនួន/ តម្លៃ |
|---|---|
| ក្រុមកសិករ (ក) | ១០០០គោ/ក្របី/ ឃុំ |
| ទុនសម្រាប់ទីកន្លែងបង្ហាញ (ខ) | $១០០ |
| ការបណ្តុះបណ្តាលក្រុមកសិករ (គ)<br>- ឯកសារ/ ការណែនាំពីបច្ចេកវិទ្យា TIP | $២០០ |
| ទិវាស្រែ - សំភារៈ (ឃ) | $២៥០ |
| មន្ត្រីកសិកម្មស្រុក-ប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ (ង)<br>- ការបណ្តុះបណ្តាល / ការត្រួតពិនិត្យទីកន្លែងធ្វើបង្ហាញ | $១៧៥ |
| មន្ត្រីកសិកម្មស្រុក-ប្រាក់ឧបត្ថម្ភ ថ្លៃធ្វើដំណើរ (ច) | $១០០ |
| ការចុះត្រួតពិនិត្យ-តាមដាននៅមូលដ្ឋានដោយអ្នកឯកទេស (ឆ) | $៤០ |
| សរុប | **$៨៦៥** |

**ការសន្មត់ប្រើប្រាស់មាន**

ក. ក្នុង TIP មួយ មានក្រុមកសិករ (៣០ នាក់) និង ទីកន្លែងបង្ហាញ ២ កន្លែង

ខ. កម្មវិធីចាក់វ៉ាក់សាំងសត្វពាហនៈ (សាទឹក-ថ្នាក់ឃុំ) ដោយពឹងផ្អែកលើប្រព័ន្ធ (ខ័ណ្ឌប័ណ្ណ) ហើយ សំភារៈទាំងអស់ត្រូវបានឧបត្ថម្ភ/ផ្គត់ផ្គង់។ ទុនសម្រាប់វ៉ាក់សាំងការពារនេះមានរួមបញ្ចូលទាំងការធ្វើផែនការ ២ ដំណាក់ និង ការប្រជុំដើម្បីត្រួតពិនិត្យតាមដាន ២ ដំណាក់កាល។

គ. សំភារៈសម្រាប់បណ្តុះបណ្តាលបច្ចេកវិទ្យាដល់កសិករួមមាន ធុងទឹកកក តម្លៃ ៥០ដុល្លា ខិត្តប័ណ្ណ៥០ដុល្លា ផ្ទាំងរូបភាពធំ៧ ៥០ដុល្លា និងពតិមានកម្មវិធី ៥០ដុល្លា ។ មន្ត្រីផលិតកម្មសត្វ និង បសុព្យាបាលនៃការិយាល័យកសិកម្មស្រុក ចូលរួមប្រជុំ ៤ ដង រួមទាំងការចុះវាល។

ឃ. ការចាក់វ៉ាក់សាំងការពារជម្ងឺសាទឹក=២៥០ ដុល្លា (៥០០រៀល,ដូសដៀសបេ x២ដូស x១០០០ក្បាល)កម្មវិធីនេះនឹងអនុវត្តតែ៥ថ្ងៃប៉ុណ្ណោះអាចត្រូវចប់ ប៉ុន្តែត្រូវប្រើកំលាំងភ្នាក់ងារពេទ្យសត្វភូមិចំនួន១០នាក់

ង. សម្រាប់មន្ត្រីកសិកម្មស្រុក ថវិការឧបត្ថម្ភ សរុបទាំងអស់ ៥០ថ្ងៃ ដោយមានភ្នាក់ងារពេទ្យសត្វភូមិចំនួន ១០នាក់

ច. ប្រាក់ឧបត្ថម្ភសម្រាប់ធ្វើដំណើរ ២ដុល្លាសម្រាប់មួយថ្ងៃ ទាំងអស់ ៥០ថ្ងៃ

ឆ. មន្ទីរកសិកម្មខេត្ត-អ្នកឯកទេសជំនាញផ្តល់ជំនួយបច្ចេកទេស និងត្រួតពិនិត្យ-តាមដានការបណ្តុះបណ្តាល បអប

| ថវិកាសម្រាប់អនុវត្តន៍ | | | | |
|---|---|---|---|---|
| រាយឈ្មោះសម្ភារៈ | ឯកតា | តម្លៃឯកតា | ចំនួនឯកតា | តម្លៃ |
| សៀវភៅកត់ត្រាសម្រាប់បសុពេទ្យស្រុក | | | | |
| សៀវភៅកត់ត្រាសម្រាប់ភ្នាក់ងារសុខភាពសត្វភូមិ | | | | |
| កិច្ចសន្យាបសុពេទ្យស្រុក | | | | |
| ក្តារខៀនរូបភាពផ្សព្វផ្សាយ | | | | |
| **សិក្ខាសាលាក្នុងឃុំ** | | | | |
| អាហារសំរ៉ន់ | | | | |
| សម្ភារៈបណ្តុះបណ្តាល | | | | |
| ឯកសារបច្ចេកទេស | | | | |
| ផ្ទាំងរូបភាព | | | | |
| ខិត្តប័ណ្ណ | | | | |
| ប័ណ្ណតំណាងសាច់ប្រាក់ | | | | |
| **ប្រជុំកសិករ** | | | | |
| Wallcharts | | | | |
| អាហារសំរ៉ន់ | | | | |

### *៣.៥ កន្លែងអនុវត្តគំរោង*

សកម្មភាពដូចនេះ ត្រូវបានអនុវត្តនៅមូលដ្ឋានប្រពលវប្បកម្ម ដោយបានចាប់ផ្តើមនៅខេត្តបាត់ដំបងនៅក្នុងឆ្នាំ ១៩៩៩ និងរីករាលដាលពាសពេញតំបន់ខាងជើងភាគខាងលិចនៃប្រទេស។ សកម្មភាពនេះត្រូវបានឧបត្ថម្ភដោយ IFAD-supported ADESS project។

## ៤. ឧបសម្ព័ន្ធ

## *៤.១ ឧបសម្ព័ន្ធទី១  សៀវភៅសម្រាប់អ្នកគ្រប់គ្រងស្រុក*

| **ជម្ងឺសាទឹក** | | | | | | |
|---|---|---|---|---|---|---|
| សៀវភៅអ្នកគ្រប់គ្រងស្រុក<br>សៀវភៅកត់ត្រាការប្រជុំក្នុងឃុំ<br>ឈ្មោះអ្នកគ្រប់គ្រងស្រុក និងតួនាទី<br>កាលបរិច្ឆេទការប្រជុំ<br>ខេត្ត<br>ស្រុក<br>ឃុំ | | | | | | |
| បញ្ជីអ្នកចូលរួម | | | | | | |
| ល | ឈ្មោះ | | | តួនាទី | | |
| ១ | | | | | | |
| ២ | | | | | | |
| ៣ | | | | | | |
| ៤ | | | | | | |
| ៥ | | | | | | |
| ៦ | | | | | | |
| ៧ | | | | | | |
| ៨ | | | | | | |
| ៩ | | | | | | |
| ១០ | | | | | | |
| ក្រុមចាក់វ៉ាក់សាំង. ក្រុមគោលដៅត្រូវការចាក់វ៉ាក់សាំង | | | | | | |
| | ភូមិ | ឈ្មោះពេទ្យសត្វភូមិ | ក្រុមគោលដៅត្រូវចាក់វ៉ាក់សាំង(ចំនួនគោ- ក្របី) | ប្រាក់ចំណូលក្រុមគោលដៅ (រៀល) | តំរូវការវ៉ាក់សាំង (ដប) | តម្លៃចាក់វ៉ាក់សាំង (រៀល) |
| ១ | | | | | | |
| ២ | | | | | | |
| ៣ | | | | | | |
| ៤ | | | | | | |
| ៥ | | | | | | |
| ៦ | | | | | | |
| ៧ | | | | | | |
| ៨ | | | | | | |
| ៩ | | | | | | |
| ១០ | | | | | | |

## កម្មវិធីចាក់ថ្នាំការពារជម្ងឺសាទឹក

សៀវភៅអ្នកគ្រប់គ្រងស្រុក

សៀវភៅកត់ត្រាការប្រជុំក្នុងឃុំ ២

ឈ្មោះអ្នកគ្រប់គ្រងស្រុក និងតួនាទី

កាលបរិច្ឆេទការប្រជុំ

ខេត្ត

ស្រុក

ឃុំ

បញ្ជីអ្នកចូលរួម

| ល | ឈ្មោះ | | | តួនាទី | | |
|---|---|---|---|---|---|---|
| ១ | | | | | | |
| ២ | | | | | | |
| ៣ | | | | | | |
| ៤ | | | | | | |
| ៥ | | | | | | |
| ៦ | | | | | | |
| ៧ | | | | | | |
| ៨ | | | | | | |
| ៩ | | | | | | |
| ១០ | | | | | | |

ក្រុមចាក់ថ្នាំការពារ . ក្រុមគោលដៅត្រូវការចាក់ថ្នាំការពារ

| | ភូមិ | ឈ្មោះពេទ្យសត្វភូមិ | ចំនួនគោ ក្របីសរុបនៅក្នុងភូមិ | ចំនួនគោ ក្របីសរុបបានចាក់ថ្នាំការពារ | កាលបរិច្ឆេទចាក់ថ្នាំការពារ | ថវិកាសរុប (រៀល) |
|---|---|---|---|---|---|---|
| ១ | | | | | | |
| ២ | | | | | | |
| ៣ | | | | | | |
| ៤ | | | | | | |
| ៥ | | | | | | |
| ៦ | | | | | | |
| ៧ | | | | | | |
| ៨ | | | | | | |
| ៩ | | | | | | |
| ១០ | | | | | | |

## ៤.២ ឧបសម្ព័ន្ធទី២  កំណត់ត្រារបស់ភ្នាក់ងារសុខភាពសត្វភូមិ

កម្មវិធីចាក់វ៉ាក់សាំងជម្ងឺសាទឹក

សៀវភៅកត់ត្រារបស់ភ្នាក់ងារសុខភាពសត្វភូមិ

កាលបរិច្ឆេទ

ខេត្ត

ស្រុក

ឃុំ

ភូមិ

សមាជិកក្រុមភ្នាក់ងារសុខភាពសត្វភូមិ

| | ឈ្មោះ | ចំនួនគោ ក្របីសរុបបានចាក់វ៉ាក់សាំង | សរុប (រៀល) | សរុបថវិកាដែលទទួលបាន (រៀល) | សរុបថវិកាដែលជំពាក់ (រៀល) | ផ្សេងៗ |
|---|---|---|---|---|---|---|
| ១ | | | | | | |
| ២ | | | | | | |
| ៣ | | | | | | |
| ៤ | | | | | | |
| ៥ | | | | | | |
| ៦ | | | | | | |
| ៧ | | | | | | |
| ៨ | | | | | | |
| ៩ | | | | | | |
| ១០ | | | | | | |

## *៤.៣ ឧបសម្ព័ន្ធទី ៣ ខិត្តប័ណ្ណព័ត៌មានអំពីជម្ងឺសាទឹក*

គោ ក្របីរបស់អ្នក អាចស្លាប់ដោយសារ ជំងឺសាទឹក



អ្នកអាចការពារគោ ក្របីរបស់អ្នកពី ជំងឺសាទឹកបាន ដោយការចាក់ថ្នាំបង្ការ



ចាក់ថ្នាំបង្ការ មានតម្លៃត្រឹមតែ ៥០០ រៀល

គោ និង ក្របី ត្រូវតែចាក់ថ្នាំបង្ការនៅ អាយុ ៣ ខែ ៦ខែ និងរៀងរាល់ ៦-១២ខែក្រោយមក



ថ្នាំបង្ការជំងឺសាទឹកមិនអាចការពារជំងឺគោ ក្របីពីជំងឺដទៃទៀតបានឡើយ ដូចជាជំងឺ អុតក្តាមជាដើម



**ព័ត៌មានបន្ថែម សូមទាក់ទង**

**ភ្នាក់ងារសុខភាពសត្វភូមិ**

*៤.៤ ឧបសម្ព័ន្ធទី ៤  ផ្ទាំងរូបភាពសម្រាប់ផ្សព្វផ្សាយអំពីថ្ងៃចាក់វ៉ាក់សាំងជម្ងឺសាទឹក*

**ទិវាចាក់ថ្នាំបង្ការជំងឺសាទឹក**







ថ្ងៃ ខែ ឆ្នាំ :

ទីកន្លែង :

ម៉ោង :

**ថ្នាំបង្ការជំងឺសាទឹក តម្លៃ ៥០០រៀល ក្នុងមួយក្បាល**

**សូមនាំគោក្របីរបស់អ្នកមកចាក់ថ្នាំបង្ការជំងឺ**

*៤.៥ ឧបសម្ព័ន្ធទី ៥  ប័ណ្ណតំណាងសាច់ប្រាក់ ចាក់វ៉ាក់សាំងជម្ងឺសាទឹក*

**ប័ណ្ណចាក់ថ្នាំបង្ការជំងឺសាទឹក**



**តម្លៃ ៥០០ រៀល**          **ប័ណ្ណលេខ :...........**

## ៤.៦ ឧបសម្ព័ន្ធទី ៦  ខិត្តប័ណ្ណក្រោយពេលចាក់វ៉ាក់សាំងជម្ងឺសាទឹក

គោ ក្របីរបស់អ្នកបានចាក់វ៉ាក់សាំងជំងឺសាទឹក



ថ្នាំបង្ការនេះនឹងជួយការពារគោ ក្របីរបស់
អ្នកពីជំងឺសាទឹក រយៈពេល.............ខែ



អ្នកគួរតែចាក់វ៉ាក់សាំងដល់គោ ក្របីពេញវ័យម្តង ទៀត
ក្នុងរយៈពេល ......... ខែ

អ្នកគួរតែចាក់ថ្នាំបង្ការដល់គោ ក្របីរបស់អ្នកដែលមាន
អាយុតិចជាង១ឆ្នាំ ក្នុងពេល៧ខែម្តង



វ៉ាក់សាំងនេះអាចការពារបានតែជំងឺសាទឹកប៉ុណ្ណោះ
មិនអាចការពារជំងឺផ្សេងទៀតបានឡើយ



**ព័ត៌មានបន្ថែម សូមទាក់ទងភ្នាក់ងារសុខភាពសត្វភូមិ**

### ៤.៧ ឧបសម្ព័ន្ធទី ៧  ក្ដារខៀន ផ្សព្វផ្សាយពីការចាក់វ៉ាក់សាំងជម្ងឺសាទឹក



## ៤.៨ ឧបសម្ព័ន្ធទី ៨  ប័ណ្ណព័ត៌មានខ្លីៗសម្រាប់ផ្សព្វផ្សាយជម្ងឺសាទឹក

### ជំងឺសាទឹកលើហ្វូងគោនៅក្នុងភូមិ



## ការចំលងជំងឺសាទឹក និង រោគសញ្ញាជំងឺសាទឹក



សត្វដែលផ្ទុកបាក់តេរីនៅក្នុងបំពង់ក



បាក់តេរីចំលងតាមសត្វដែលផ្ទុកទៅសត្វ
ដែលមានសុខភាពល្អ

បាក់តេរីចំលងពីសត្វឈឺ ទៅ
សត្វជា





សត្វឈឺមានរោគសញ្ញាដូចជា ហើមក
និងពោះ ហៀរទឹកមាត់ និងមានសីតុណ្ហភាពខ្ពស់



សត្វនឹងងាប់ ប្រសិនបើការព្យាបាលមិន
បានទាន់ពេលវេលា